

# ហេតុការណ៍រហ័ស៖ វ៉ាក់សាំងជំងឺ COVID-19 និងការមានផ្ទៃពោះ

## មានការផ្សព្វផ្សាយព័ត៌មានមិនពិតជាច្រើនអំពីវ៉ាក់សាំងជំងឺ COVID-19 និងការមានផ្ទៃពោះ សូមបកស្រាយការពិតខ្លះៗ!

### វ៉ាក់សាំងជំងឺ COVID-19 គឺមានសុវត្ថិភាពមុនពេល អំឡុងពេល និងក្រោយពេលមានផ្ទៃពោះ។

ការចាក់វ៉ាក់សាំងអំឡុងពេលមានផ្ទៃពោះត្រូវបានណែនាំដោយ American College of Obstetricians and Gynecologists (ACOG, មហាវិទ្យាល័យសម្ភព និងរោគស្ត្រីរបស់អាមេរិក) និង Centers for Disease Control and Prevention (CDC, មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ) ដើម្បីផ្តល់ការការពារប្រឆាំងនឹងជំងឺ COVID-19 ធ្ងន់ធ្ងរ។

### អ្នកដែលមានផ្ទៃពោះមានហានិភ័យខ្ពស់ចំពោះការប្រឈមនឹងជំងឺធ្ងន់ធ្ងរ និងមានផលវិបាក ប្រសិនបើពួកគេកើតជំងឺ COVID-19។

ការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 អំឡុងពេល ឬក្រោយពេលមានផ្ទៃពោះអាចបង្កើនហានិភ័យយ៉ាងខ្លាំងដល់ការចូលព្យាបាលនៅមន្ទីរពេទ្យដែលតម្រូវឱ្យប្រើបំពង់ដកដង្ហើម ជួបផលវិបាកអំឡុងពេលមានផ្ទៃពោះ កំណើតមិនគ្រប់ខែ ឬការសម្រាលកូនមិនទាន់គ្រប់ខែ។

### មិនមានភ័ស្តុតាងណាមួយដែលបង្ហាញថាវ៉ាក់សាំងជំងឺ COVID-19 បង្កឱ្យមានពិការភាពពីកំណើត ការរលូតកូន កំណើតមិនគ្រប់ខែ ការសម្រាលកូនមិនទាន់គ្រប់ខែ ឬផលវិបាកផ្សេងទៀតនោះទេ។

ទោះបីជាយ៉ាងណាក៏ដោយ ជំងឺ COVID-19 ត្រូវបានគេដឹងថា បណ្តាលឱ្យមានផលវិបាកទាំងនេះ។

### អ្នកអាចមានសុវត្ថិភាពដើម្បីទទួលការចាក់វ៉ាក់សាំងនេះ ប្រសិនបើអ្នកកំពុងបំបៅដោះកូន។

ទឹកដោះម្តាយអាចផ្ទេរអង្គបដិប្រាណទៅឱ្យកូនរបស់អ្នក ដើម្បីជួយការពារពួកគេពីការឆ្លងជំងឺ COVID-19 រហូតដល់ពួកគេមានសិទ្ធិទទួលការចាក់វ៉ាក់សាំងនៅអាយុ 6 ខែ។


**ធនធាន៖**

វ៉ាក់សាំងជំងឺ COVID-19 អំឡុងពេលមានផ្ទៃពោះ ឬបំបៅដោះកូន (cdc.gov) | https://www.cdc.gov/coronavirus/2019-ncov/vaccines/recommendations/pregnancy.html (ជាភាសាអង់គ្លេស អេស្បាញ កូរ៉េ វៀតណាម និងចិនតែប៉ុណ្ណោះ)

ស្ត្រីមានផ្ទៃពោះ និងទើបមានផ្ទៃពោះថ្មីៗ | CDC | https://www.cdc.gov/coronavirus/2019-ncov/need-extra-precautions/pregnant-people.html (ជាភាសាអង់គ្លេសប៉ុណ្ណោះ)

វ៉ាក់សាំងជំងឺ COVID-19 និងការមានផ្ទៃពោះ៖ អ្វីដែលអ្នកត្រូវដឹង | Johns Hopkins Medicine | https://www.hopkinsmedicine.org/health/conditions-and-diseases/coronavirus/the-covid19-vaccine-and-pregnancy-what-you-need-to-know (ជាភាសាអង់គ្លេសតែប៉ុណ្ណោះ)



Washington State Department of Health

DOH 825-049 July 2022 Khmer


ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 1-800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។

Vaccinate WA

CovidVaccineWA.org